# ស្តាប់ភ្លេងខ្លងខែក

(បទពាក្យ៨)

អង្គព្រះទិនករចរចាំងរស្មី    ព្រឹកម៉ោងប្រាំបីតាមដងមាគ៌ា
មនុស្សហូរហែយាត្រាលីលា    តម្រៀបជួរគ្នាកាន់ធូបទៀនផ្កា។
សំលេងខ្លងខែកស្រែកថ្ងូររងំ    ដង្ហោយត្អូញយំជ្រែកអាកាសា
លន្លង់លន្លោចដូចតឹងឱរា    អាណិតវាសនាជីវិតលោកីយ៍។
មើលចុះជីវិតពិតជាមិនទៀង    ជូនអ្នកជូននាងជូនរាស្ត្រមន្ត្រី
ថ្ងៃនេះជួបជុំសើចលេងប្រិមប្រិយ    ស្អែកចូលដល់ថ្មីបាត់រូបកាយា។
ខ្សែជីវិតនេះប្រហែសមិនបាន    យុវវ័យគ្រប់ប្រាណគួរគិតវិចារណ៍
ត្រូវប្រុងប្រយ័ត្នជាប់ក្នុងចិន្តា    ភ្លើតភ្លើនហ៊ឺហាក្រែងធ្លោយស៊ិយកាយ។
គ្រប់ពេលត្រាច់ចរបរយានរថយន្ត    កុំភ័យខ្លាចអន់តាំងអួតលយឆាយ
បង្ហោះហ៊ឺហាអួតមិត្តទាំងឡាយ    ចង្កះនាយអាយកាច់អួតគេឯង។
ល្បឿនតិចមិនចង់កង់មិនជក់ខ្យល់    ថែមល្បឿនអោយដល់ធ្វើឫកខែងរ៉ែង
ភ្លាត់ស្មៀតខ្ទាតរឹងបាត់មាត់លែងថ្លែង    អស់ឫទ្ធិ៍សំដែងខ្លងខែកស្រែកហត់។
គ្រប់ការសប្បាយកុំភ្លាយឃ្លាតគិត    សប្បាយពេកពិតច្រើនទុក្ខប្រាកដ
ទាំងល្បែងកាមគុណបើចង់ខំអត់    មានដែនកំណត់ផុតរោគមរណា។
ប្រហែសនឹងបាត់ប្រយ័ត្នទើបគង់    ប្រមាទលិចលង់ក្នុងជ្រោះអន្ធការ
ជីវិតផុយណាស់គួរគិតផងណា    អាណិតយាយតាអ្នកជួយដង្ហែ។✍

*(២៦ តុលា ២០០២)*

*ភិក្ខុ ស្វាត សាលឿម*